ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ៣៣៩

ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៣

នាមនាមប្រជារាស្ត្រខ្មែរ

សាលដីកា

តុលាការកំពូល

លេខ : ១៣០

ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៤

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឌិត | មុន្ទី | ជាប្រធាន |
| ២-លោក | ប្រាក់ | គឹមសាន | ជាចៅក្រមរបាយការណ៍ |
| ៣-លោក | ជីវ | កេង | ជាចៅក្រម |
| ៤-លោក | យស់ | សូខឿន | ជាចៅក្រម |
| ៥-លោក | ម៉ុង | មុនីចរិយា | ជាចៅក្រម |

ក្រឡាបញ្ជី

កញ្ញា ហុក សុខធុល

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ១០៤"យ" ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២២៦ ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **ស្រី ក្រេង** (ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៧៥ឆ្នាំ ជាតិខ្មែរ មុខរបរគណៈកម្មការវត្តនិរោធ ទីលំនៅសព្វថ្ងៃភូមិតាម៉ៅ ឃុំនិរោធ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ។ ឳពុកឈ្មោះស្រី ប៉ុក "ស" ម្តាយឈ្មោះខូង ឆាយ"ស" ប្រពន្ធឈ្មោះ ជា ណាម "ស" មានកូន ០៦នាក់ ។

មានមេធាវីលោក កែវ យ៉ា ។

ចុងចំលើយឈ្មោះ **ថូន ស៊ីថន** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅភូមិតាម៉ៅ សង្កាត់និរោធ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឳពុកឈ្មោះ ថន ចុន "រ" ម្តាយឈ្មោះគុប ខុម "រ" ប្រពន្ធឈ្មោះសុង សុវណ្ណ ។

**កម្មវត្ថុបណ្ដឹង** : ប្ដឹងសុំឱ្យចេញពីដីវត្ត និងបញ្ឈប់ការដាំដុះនៅក្នុងវត្ត ។

បានឃើញបណ្ដឹងសាទុក្ខលេខ៨៧៥ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះថូន ស៊ីថន ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១០៤"ឃ"ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣៩ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី២០-៩-១៩៩៩ របស់ឈ្មោះ ស្រី គ្រេង ប្ដឹងសុំឱ្យចេញពីដីវត្ត និងបញ្ឈប់ការដាំដុះនៅក្នុងវត្តដោយសំអាងហេតុថា : កន្លងមកពីឆ្នាំ១៩៧៩ ក្រោយពេលរំដោះវត្តនិរោធរង្សី ត្រូវបានបើកឱ្យមានព្រះសង្ឃគង់នៅ និង ពុទ្ធបរិសទគោរពប្រតិបត្តិ ។ ក្រោយមកអំឡុងឆ្នាំ១៩៩០ ឈ្មោះ នាង សុខុម បានទៅសុំព្រះតេជគុណចៅអធិការវត្តនិរោធរង្សី ព្រះនាមអ៊ុយ ដើម្បីដាំដំណាំនៅលើដីស្ថិតនៅខាងលិចជាប់នឹងផ្លូវចូលវត្តប្រជុំវង្ស ។ ព្រះតេជគុណ ដោយយល់ឃើញថា ពុទ្ធបរិសទមានការខ្វះខាតខាងជីវភាពក៏អនុញ្ញាតិឱ្យដាំលើដីនោះ ។ ឥឡូវនេះ ព្រះតេជគុណចៅអធិការវត្តព្រះនាមអ៊ុយ លោកបានទទួលអនិច្ចកម្មទៅហើយៗក្រុមគ្រួសារនេះ ដែលមានឈ្មោះថូន ស៊ីថន ជាអ្នកចេញមុខអះអាងថា ដីនេះជាដីដែលខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៧៩មកម្ល៉េះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៥"ជ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី២០-៩-១៩៩៩ របស់ដើមចោទឈ្មោះ ស្រី គ្រេង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹងតបចុះថ្ងៃទី១៥-៥-២០០០របស់ចុងចម្លើយឈ្មោះថូនស៊ីថន ទុកជាត្រឹមត្រូវទំរង់ តែបដិសេធចោលដោយផ្ទុយពីគតិច្បាប់ ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ៧.០០០រៀល គឺពន្ធចុះបញ្ជីក្ដី ពន្ធហ្វឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ សរុប ៧.០០០៛ ។ ប្រាក់នេះកាត់យកពីប្រាក់ដែលថូន ស៊ីថន បានបង់ទុករួចជាស្រេច ។

៤-ប្រគល់ដីទំនាស់ដែលថូន ស៊ីថន និង គ្រួសារកំពុងកាន់កាប់ថែរក្សា និងប្រើប្រាស់ ទៅឱ្យគណៈកម្មការអាចារ្យវត្តនិរោធរង្សី គ្រប់គ្រងជាសម្បត្តិវត្តវិញ ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅ តាមមាត្រា ៥, ៥៦, ៥៧, និង៥៨ នៃច្បាប់ភូមិបាល ។

៥-ឱ្យចុងចម្លើយឈ្មោះថូន ស៊ីថន សងប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី ពន្ធហ្វឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ សរុប

៧.០០០៛ ។ ប្រាក់នេះកាត់យកពីប្រាក់ដែលដើមចោទបានបង់ទុករួចជាស្រេច ។ លុះផុតបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយបង់សងដើមចោទវិញ និង ឱ្យបង់ពន្ធសមាមាត្រ១% លើតំលៃដីជាក់ស្តែងនៃដីទំនាស់ ។

៦-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១០"ឆ" ចុះថ្ងៃទី២៣ ខែ មេសា ឆ្នាំ២០០១ របស់ឈ្មោះ ចូន ស៊ីថន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៥"ឆ" ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១០៤"យ" ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ចូន ស៊ីថន ចុះថ្ងៃទី២៣-៤-២០០១ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១៥"ឆ" ចុះថ្ងៃទី ២៣-៤-២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលដើមចោទបង់ជួស គឺពន្ធចុះបញ្ជីក្តី ពន្ធហ្វឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ ។

-បង្គាប់ឱ្យចុងចម្លើយសងប្រាក់ប្រដាប់ក្តីចំនួន ១៣.០០០៛ ទៅឱ្យដើមចោទវិញ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៤៧៥ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះចូន ស៊ីថន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១០៤"យ"ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ឈ្មោះចូន ស៊ីថន ។

បានឃើញសារណាតបចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះស្រី គ្រេង ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះពុំត្រឹមត្រូវទេ ។ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តា ពិនិត្យ និងសំរេច ។

បានស្តាប់ចំលើយរបស់ឈ្មោះចូន ស៊ីថន នាពេលសវនាការថា ៖ បានជាខ្លួនប្តឹងសាទុក្ខ ព្រោះមិនសុខចិត្តនឹងសេចក្តីសំរេចរបស់តុលាការក្រុងភ្នំពេញ និង សាលាឧទ្ធរណ៍ ព្រោះថា ដីនេះខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ ឯវត្តមានតែលិខិតបញ្ជាក់តែប៉ុណ្ណោះ មិនបានកាន់កាប់ទេ ។ ដីនេះនៅឆ្ងាយពីដីវត្ត មិននៅក្នុងរបងវត្តទេ ដីនេះ ខ្លួនបានដាំដើមសសេក និងដើមឫស្សីធ្វើជារបងដែលមានទំហំ ៤៩ម គុណ ៣១ម ការវត្តចោទថា ៖ ម្តាយខ្លួនមានខ្ចីដីនេះពីវត្តនោះ គឺជាការពុំត្រឹមត្រូវទេ ព្រោះម្តាយខ្លួនមិនបានខ្ចីទេ គឺកាប់ឆ្ការដោយខ្លួនឯង ។ ហើយចំពោះដីនេះ ខ្លួនគ្មានចុងសន្លឹកមកពីឪពុកខ្លួនមានទំនាស់ជាមួយលោក ម៉ា ឡូញ ហើយពេលទៅដាក់ពាក្យសុំ គាត់ពុំធ្វើអោយ ។ ខ្លួនសូមសំណូមពរតុលាការ មេត្តាបដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់លោក ស្រី ក្រេង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក កែវ យ៉ា ជាមេធាវីការពារឱ្យដើមចោទ នាពេលសវនាការថា ៖ វត្តកើតមានតាំងពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៧៥ ត្រូវរបបប៉ុលពតទមិឡកាន់កាប់ ត្រូវលុបបំបាត់វត្តអស់ តែដល់ឆ្នាំ១៩៨០ វត្តក៏បានកើតមានវិញ ។ នៅឆ្នាំ១៩៨៥-៨៦ ឈ្មោះគុប ខុម ត្រូវជាម្តាយឈ្មោះចូន ស៊ីថន បានមកសុំខ្ចីវត្ត គឺបានសុំខ្ចីពីចៅអធិការព្រះនាមស្វាយ អ៊ុយ ហើយនៅឆ្នាំ១៩៨៨ វត្តបានច្បាប់ត្រូវធ្វើរបងព័ទ្ធជុំវិញ តែឈ្មោះគុប ខុម បានហាមឃាត់មិនឱ្យសាងសង់ដោយសំអាងថា គាត់បានកាន់កាប់តាំងពីឆ្នាំ១៩៧៩ ។

តាមពិតដីវត្តមានព្រំប្រទល់ ខាងកើតទល់នឹងវិទ្យាល័យច្បារអំពៅ ខាងលិចទល់ផ្លូវលំចូលវត្តប្រជុំវង្ស ខាងជើងទល់ផ្លូវជាតិលេខ១និងខាងត្បូងទល់ព្រែកបារាំង ។ ខ្លួនសូមជំរាបតុលាការថា វត្តមានភស្តុតាង និង ឯកសារគ្រប់គ្រាន់ ដូចបានជំរាបនៅក្នុងសារណា គឺលិខិតបញ្ជាក់របស់មន្ទីរធម្មការខ័ណ្ឌមានជ័យ មន្ទីរធម្មការក្រុងភ្នំពេញ បានបញ្ជាក់ច្បាស់លាស់ពីព្រំប្រទល់ដីវត្ត ជាពិសេសគឺសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ដែលចុះហត្ថលេខា និង ត្រា ដោយនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ ជាដើម ។ ដូច្នេះ ដីវត្តនេះមានច្បាប់ការពាររួចហើយ ។ ខ្លួនសូមសំណូមពរតុលាការមេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

បានស្តាប់ចំលើយរបស់ឈ្មោះ ចូន ស៊ីថន បានបន្ថែមទៀតថា ៖ ខ្លួនសុំជំទាស់សំដីលោកមេធាវី និងសារណាដែលក្រឡាបញ្ជីអានអំបាញ់មិញនេះថា ៖ ចំពោះប្លង់ និងច្បាប់ធ្វើរបងនេះ គឺធ្វើតាមផ្លូវជាតិលេខ១ទេ មិនមែនដីខ្លួនទេ ហើយរបងដែលលោកមេធាវីបង្ហាញនេះ គឺទើបតែនឹងសាងសង់ទេ ។ ចំពោះរឿងធ្វើប័ណ្ណកម្មសិទ្ធិនេះ គឺឪពុកខ្លួនមានទំនាស់ជាមួយលោក ម៉ា ឡូញ ពិតប្រាកដមែន បានជាគាត់មិនចេញប័ណ្ណនេះឱ្យ ។ ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យគ្រួសារខ្លួនផង ព្រោះគ្រួសារខ្លួនរងទុក្ខវេទនាខ្លាំងណាស់ ខ្លួនសុំឱ្យតុលាការកាត់ដីនេះឱ្យខ្លួនបានរស់នៅដូចប្រជាជនផ្សេងទៀតផង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី កែវ យ៉ា បានបន្ថែមទៀតថា : ក្នុងការសុំសិទ្ធិកាន់កាប់ដី បើឪពុកគាត់មានទំនាស់ គឺជាទំនាស់បុគ្គល អ្នកផ្សេងទៀតអាចសុំបាន ។ ដីនេះមិនឃ្លាតឆ្ងាយពីវត្តទេ គឺនៅជាប់ផ្លូវចូលវត្តប្រជុំវង្ស ខ្លួនបានសុំឱ្យតុលាការពិចារណាលើរូបថតនេះ និងសុំឱ្យតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយលោកថូន ស៊ីថន ,សារណារបស់លោកស្រី ក្រេង និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីលោក ស្រី ក្រេង .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៧៥ ចុះថ្ងៃទី ១៩-១២-២០០២ របស់លោក ថូន ស៊ីថន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចជា តុលាការក្រុងភ្នំពេញ សំរេចប្រគល់ដីទំនាស់ទៅឱ្យគណៈកម្មការអាចារ្យវត្ត និរោធរង្សី គ្រប់គ្រងជាសម្បត្តិវត្ត ដោយអាងហេតុថា : ដីទំនាស់ស្ថិតនៅក្នុងបរិវេណវត្តនិរោធរង្សីនោះ ពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់ទេ ពីព្រោះថា :

+ ដីទំនាស់ ពុំមានប្លង់បង្ហាញទីតាំង គូរដោយសមត្ថកិច្ចជំនាញច្បាស់លាស់ទេ។

+ ក្នុងពាក្យបណ្តឹងក៏ដូចនាសវនាការនៅសាលាឧទ្ធរណ៍ និងតុលាការថ្នាក់ក្រោម ដើមចោទពុំបានបញ្ជាក់អំពីទំហំដីពិតប្រាកដ ហើយក្នុងកំណត់ហេតុផ្សះផ្សាសំរុះសំរួលថ្ងៃទី០៨-៥-២០០០ ដើមចោទអះអាងថា មានប្រវែងជាង ៣០ម ជំរៅជាង ២០ម ឯចម្លើយរបស់ចុងចម្លើយក៏មានការប្រែប្រួលដែរ នៅពេលផ្សះផ្សាថា មានប្រវែង៤០ម ជំរៅជាង២០ម នាសវនាការនៅតុលាការថ្នាក់ក្រោម និងសាលាឧទ្ធរណ៍ថា ដីទំនាស់មានទំហំ ៤៨ម x ៣១ម ។

+ តាមប្លង់បង្ហាញទីតាំងដីទំនាស់ គូរដោយចុងចម្លើយ ដីទំនាស់ស្ថិតនៅឃ្លាតឆ្ងាយពីព្រំខាងលិចវត្ត ហើយក៏ស្ថិតក្នុងជួរផ្ទះប្រជាជនផ្សេងទៀត តាមបណ្តោយផ្លូវចូលទៅកាន់វត្តប្រជុំវង្ស ។

- យល់ឃើញថា លោក ស្រី ក្រេង បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១០៤"យ"ចុះថ្ងៃទី១៦-១២-២០០២ របស់

សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខលោក ជួន ស៊ីថន**

**កំបាំងមុខលោក ស្រី ក្រេង ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ ៤៧៥ ចុះថ្ងៃទី១៩-១២-២០០២ របស់លោកជួន ស៊ីថន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១០៤"ឃ" ចុះថ្ងៃទី១៦-១២-២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល .

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣៩ ចុះថ្ងៃទី០១-៩-២០០៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលលោក ស្រី ក្រេង បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៤។